# គោលការណ៍ណែនាំ
# សម្រាប់
# ក្រុមគ្រូបង្គោលថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាល
# ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

## ១. សាវតា

ការកសាងសមត្ថភាពគឺជាចំនុចគន្លឹះដើម្បីបញ្ជ្រាបសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងការរៀបចំ គោល-នយោបាយ យុទ្ធសាស្ត្រជាតិ និងដំណើរការកសាងផែនការវិមជ្ឈការ ក៏ដូចជារៀបចំកំណត់តំបន់គោលដៅសម្រាប់ការធ្វើអន្តរាគមន៍ផ្សេងៗ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.) ដោយមានការគាំទ្រពីអង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) ក្នុងក្របខ័ណ្ឌកម្មវិធីភាពជាដៃគូរវាងអង្គការ FAO និងដៃគូអភិវឌ្ឍន៍ចម្រុះ (FAO Multi-Donor Partnership Program-FMPP) និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត បានផ្តួចផ្តើមគំនិតបង្កើតក្រុមគ្រូបង្គោលថ្នាក់ជាតិមួយ ដើម្បីផ្តល់ការយល់ដឹង និងបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដល់មន្ត្រីជំនាញមកពីស្ថាប័នពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍន៍ជនបទ ការរៀបចំគោលនយោបាយ និងការធ្វើផែនការ។ ក្រុមគ្រូបង្គោលថ្នាក់ជាតិស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក.ក.ជ. ជាប្រធាន។

ក្រុមគ្រូបង្គោលថ្នាក់ជាតិនេះ ជាយន្តការមួយសម្រាប់ផ្តល់ចំណេះដឹង និងការកសាងសមត្ថភាពដែលពាក់ព័ន្ធទៅនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ ក្រុមគ្រូបង្គោលនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីធានាបាននូវស្តង់ដាគំរូមួយសម្រាប់ការបណ្តុះបណ្តាល និងដើម្បីធានាបាននិរន្តរភាពនៃដំណើរការកសាងសមត្ថភាព។ ជាមួយគ្នានេះ កម្មវិធីបណ្តុះបណ្តាល ក៏ត្រូវបានរៀបចំឡើងយ៉ាងផ្ចិតផ្ចង់សម្រាប់សេវាបណ្តុះបណ្តាលគ្រប់កម្រិតដោយផ្អែកលើបទពិសោធន៍ និងចំណេះដឹងយ៉ាងទូលំទូលាយលើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ក្រុមគ្រូបង្គោលនេះមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាបណ្តុះបណ្តាលដល់មន្ត្រីជំនាញមកពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជននានា ដែលធ្វើការងារពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងជំនាញពាក់ព័ន្ធផ្សេងៗទៀត។ ស្ថាប័នឬអង្គការណា ដែលមានបំណងចង់បានសេវាកម្មបណ្តុះបណ្តាលរបស់ក្រុមគ្រូបង្គោល សូមទាក់ទងមកអគ្គលេខាធិការដ្ឋានក.ក.ជ.។ ព័ត៌មានលម្អិតស្តីអំពីជំនាញ និងបទពិសោធន៍របស់សមាជិកក្រុមគ្រូបង្គោលមានផ្តល់ជូនតាមរយៈវេបសាយសន្តិសុខ-ស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា (http://www.foodsecurity.gov.kh/Trainer_Pool.aspx)។

គោលការណ៍ណែនាំនេះមានគោលបំណងដើម្បីសម្របសម្រួលក្នុងការជ្រើសរើសសមាជិកក្រុមគ្រូបង្គោល និងសម្របសម្រួលសេវាបណ្តុះបណ្តាលផ្សេងៗរវាងស្ថាប័នដែលស្នើ ក្រុមគ្រូបង្គោល និង ក.ក.ជ. ។

## ២. គោលដៅ និងគោលបំណង

គោលដៅរបស់ក្រុមគ្រូបង្គោល គឺដើម្បីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងការអភិវឌ្ឍធនធានមនុស្សដើម្បីកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។

**គោលបំណងរបស់ក្រុមគ្រូបង្គោលរួមមាន:**

១- ធានានូវកម្មវិធីបណ្តុះបណ្តាលមួយដែលមានគុណភាពខ្ពស់តាមរយៈការអភិវឌ្ឍបន្ថែមទៀតនៃកម្មវិធីបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

២- ធានាឱ្យមានក្រុមគ្រូបង្គោលដែលមានសមត្ថភាពអាចផ្តល់ការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធ។

៣- ពិនិត្យតាមដានលទ្ធផលនៃការកសាងសមត្ថភាពលើផ្នែកសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅគ្រប់កម្រិត។

៤- ធ្វើការផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនពីក្រុមគ្រូបង្គោលថ្នាក់ជាតិ និងកម្មវិធីបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

៥- ជម្រុញឱ្យមានការគាំទ្រ និងប្រើប្រាស់កម្មវិធីបណ្តុះបណ្តាល និងក្រុមគ្រូបង្គោល ដោយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ពីក្រុមគ្រូបង្គោលថ្នាក់ជាតិ ។

ការប្រើប្រាស់ក្រុមគ្រូបង្គោលនេះ នឹងធ្វើឱ្យមានលទ្ធផលជាវិជ្ជមានលើសកម្មភាពអន្តរាគមន៍ផ្សេងៗ និងចូលរួមចំណែកផងដែរដល់ការបង្កើនសមត្ថភាពដល់បុគ្គលិកតាមមូលដ្ឋាន ជាពិសេសអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នករៀបចំផែនការនៅថ្នាក់ក្រោមជាតិ។

## ៣. កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលចំនួន៤ប្រភេទផ្សេងៗគ្នាដែលមានលក្ខណៈស្តង់ដារ ត្រូវបានបង្កើតឡើង និងបានធ្វើតេស្តសាកល្បងនៅក្នុងឱកាសផ្សេងៗនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់នេះអាចត្រូវយកមកពិនិត្យ និងកែសម្រួលឡើងវិញដើម្បីឱ្យឆ្លើយតបតាមតម្រូវការរបស់ក្រសួង-ស្ថាប័ន ដែលបានស្នើ ឬតាមស្ថានភាពចាំបាច់នៅក្នុងតំបន់គោលដៅនីមួយៗ ។ ការពិនិត្យ និងកែសម្រួលកម្មវិធីបណ្តុះបណ្តាលឡើងវិញលើកទីមួយត្រូវបានធ្វើឡើងដោយសមាជិកក្រុមគ្រូបង្គោលខ្លួនឯងផ្ទាល់ ដោយមានជំនួយបន្ថែម ពីអ្នកជំនាញការអន្តរជាតិផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភមកពីមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិ (InWEnt) នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។ គ្រូបណ្តុះបណ្តាលទាំងនោះបានឆ្លងកាត់វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិជាច្រើនស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងកំពុងអនុវត្ត ការបណ្តុះបណ្តាល

ដាក់ស្តែងនៅគ្រប់កម្រិតក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤. ការប្រើប្រាស់ក្រុមគ្រូបង្គោលថ្នាក់ជាតិ

*តើអ្នកណាខ្លះដែលអាចប្រើប្រាស់ក្រុមគ្រូបង្គោលថ្នាក់ជាតិ?*

ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនទាំងអស់ដែលមានបំណងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មិនថានៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានអាចប្រើប្រាស់ក្រុមគ្រូបង្គោលថ្នាក់ជាតិ ដោយគ្រាន់តែទាក់ទងមក ក.ក.ជ.។ បញ្ជីឈ្មោះនិងព័តិមានលំអិតនៃសមាជិកក្រុមគ្រូបង្គោលនីមួយៗមានផ្តល់ជូននៅលើគេហទំព័រប្រព័ន្ធព័តិមានស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា (http://www.foodsecurity.gov.kh/Trainer_Pool.aspx) ។

*តើគ្រូបង្គោលត្រូវបានស្នើ និងជ្រើសរើសសម្រាប់ផ្តល់ការបណ្តុះបណ្តាលតាមរបៀបណា?*

ស្ថាប័នស្នើសុំនឹងតម្រូវឱ្យធ្វើទំនាក់ទំនងមកកាន់អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. ដើម្បីពិភាក្សា និងរៀបចំនិតិវិធីដែលមាន ព្រមទាំងសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារដែលមានបញ្ជាក់ពីរយៈពេលនៃដំណើរការបណ្តុះបណ្តាល (រួមបញ្ចូលទាំងថ្ងៃរៀបចំមុនវគ្គបណ្តុះបណ្តាល ចំនួនថ្ងៃដាក់ស្តែងសម្រាប់សកម្មភាពបណ្តុះបណ្តាល និងចំនួនថ្ងៃនៅមូលដ្ឋាន) ដើម្បីងាយស្រួលវាយតម្លៃសម្រាប់វគ្គ និងអត្រាតម្លៃប្រចាំថ្ងៃរបស់គ្រូ។ អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. នឹងធ្វើលិខិតផ្លូវការទៅស្ថាប័នសាមី របស់គ្រូបង្គោលដើម្បីស្នើសុំអញ្ជើញគ្រូបណ្តុះបណ្តាល មកចូលរួម។

កិច្ចសន្យា នឹងត្រូវចុះហត្ថលេខារវាងអគ្គលេខាធិការនៃក.ក.ជ. ឬតំណាង និងស្ថាប័នស្នើសុំ។

*តើតម្លៃអ្វីខ្លះ ដែលនឹងត្រូវគិតបញ្ចូលទៅក្នុងសេវាបណ្តុះបណ្តាល?*

គ្រូបង្គោលម្នាក់ៗត្រូវទទួលប្រាក់កំរៃប្រចាំថ្ងៃ តាមអត្រាដែលបានព្រមព្រៀង ដូចមានចែងក្នុងកិច្ចសន្យាប៉ុន្តែមិនត្រូវទាបជាង ៥០ (ហាសិប) ដុល្លារសហរដ្ឋអាមេរិកឡើយ។ អាត្រាកំរៃប្រចាំថ្ងៃនេះមានប្រកាសផ្សាយនៅក្នុងវិបសាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ បន្ថែមពីលើនេះ ស្ថាប័នដែលស្នើត្រូវផ្តត់ផ្គង់ថ្លៃធ្វើ ដំណើរ ថ្លៃហូប ចុក ស្នាក់នៅ (ប្រសិនបើជាតម្រូវការ) និងថ្លៃធានារ៉ាប់រងនៅក្នុងរយៈពេលបំពេញការងារ។

ស្ថាប័នដែលស្នើ ត្រូវផ្គត់ផ្គង់ផងដែរនូវថ្លៃសំភារៈបណ្តុះបណ្តាលដូចជា ក្រដាស ក្រដាសផ្ទាំងធំ ប៊ិច ។ល។ ឬសម្ភារៈ និងបរិក្ខារផ្សេងៗទៀតដែលត្រូវការចាំបាច់នៅពេលបណ្តុះបណ្តាល។

*តើអ្នកណាជាអ្នកគ្រប់គ្រង និងចាត់ចែងក្រុមគ្រូបង្គោលថ្នាក់ជាតិ?*

អគ្គលេខាធិការដ្ឋាន នៃ ក.ក.ជ. ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងក្រុមគ្រូបង្គោលដោយសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដែលពាក់ព័ន្ធ។ ភារកិច្ច និងការទទួលខុសត្រូវរបស់ អគ្គលេខាធិការដ្ឋាន នៃ ក.ក.ជ. មានដូចតទៅ:

- ធានានូវទំនាក់ទំនងដោយរលូន ជាមួយស្ថាប័នដែលស្នើសុំសេវាបណ្តុះបណ្តាលក្រុមគ្រូង្គោល និងនិយោជក ឬសាមីក្រសួងរបស់គ្រូបង្គោល

- គ្រប់គ្រង និងពិនិត្យគុណភាពនៃកម្មវិធីបណ្តុះបណ្តាលដែលបានបង្កើត
- ជួយគ្រូបង្គោលដើម្បីកែលម្អសេវាបណ្តុះបណ្តាល និងជួយផ្សព្វផ្សាយអំពីចំណុចខ្លាំង និងសមត្ថភាពជំនាញពិសេសរបស់សមាជិកក្រុមគ្រូបង្គោល *(សូមមើលចំនុចទី៧ : ការពិនិត្យ តាមដាន និងវាយតម្លៃ )* ដល់ស្ថាប័នផ្សេងៗជាអតិថិជន
- សម្របសម្រួលជាមួយនិយោជក ឬស្ថាប័នសាមីរបស់គ្រូបង្គោល និងបញ្ជាក់ពីអត្ថប្រយោជន៍ នៃសេវាកម្មបណ្តុះបណ្តាល ដោយស្នើសុំឱ្យគ្រូបង្គោលបានចូលរួមវគ្គបណ្តុះបណ្តាលឱ្យបានញឹកញាប់
- គ្រប់គ្រង និងប្រើប្រាស់វិភាគទានដែលទទួលបានពីសមាជិកក្រុមគ្រូបង្គោល និងថវិកាដែលទទួលបានពីប្រភពផ្សេងៗទៀត ព្រមទាំងសម្ភារៈ និងទ្រព្យសម្បត្តិនានា ប្រកបដោយប្រសិទ្ធភាព និង តម្លាភាព
- ធ្វើរបាយការណ៍បូកសរុបប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពបណ្តុះបណ្តាលរបស់ក្រុមគ្រូបង្គោល និងអនុសាសន៍នានាពីស្ថាប័នដែលបានទទួលសេវាកម្មបណ្តុះបណ្តាល ។

## ៥.លក្ខណៈវិនិច្ឆ័យ និងតម្រូវការសម្រាប់សមាជិកភាពនៃក្រុមគ្រូបង្គោល

អ្នកដែលមានបំណងចង់ក្លាយជាសមាជិកក្រុមគ្រូបង្គោលថ្នាក់ជាតិត្រូវមានលក្ខណៈសម្បត្តិ និងឆ្លងកាត់ការជ្រើសរើសដូចខាងក្រោម៖

### ក. លក្ខណៈសម្បត្តិ

- អ្នកដែលបានទទួលបានការបណ្តុះបណ្តាលក្នុង ឬក្រៅប្រទេសដែលទាក់ទងទៅនឹងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ទាំងវគ្គយល់ដឹងទូទៅ និងវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល
- អ្នកដែលធ្លាប់មានប្រវត្តិជាគ្រូបណ្តុះបណ្តាល ឬជាអ្នកសម្របសម្រួល ហើយមានចំណេះដឹង និងមានបទពិសោធន៍ច្រើនទាក់ទង នឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- អ្នកដែលមានសមត្ថភាព និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមផ្តល់សេវាបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយមានកិច្ចសហការពី ក.ក.ជ.។

### ខ. ការជ្រើសរើស

សមាជិកក្រុមគ្រូបង្គោលនឹងត្រូវជ្រើសរើសតាមរយៈគណៈកម្មាធិការមួយដែលរួមមានតំណាងមកពី ក.ក.ជ. និងស្ថាប័នដែលដែលផ្តល់ការឧបត្ថម្ភគាំទ្រដល់ក្រុមគ្រូបង្គោល ។

### គ. សមាជិកក្រុមគ្រូបង្គោលដែលមានបច្ចុប្បន្ន

| ល.រ | ឈ្មោះ | ស្ថាប័ន |
|---|---|---|
| ០១ | **ឯ.ឧ រ័ត្ន វីរៈ**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៩២១ ៩៩៩<br>អ៊ីម៉ែល: virakrath@hotmail.com | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី |

| | | |
|---|---|---|
| ០២ | **ឯ.ឧ ស្រ៊ុន ដារិទ្ធិ**<br>លេខទូរស័ព្ទ:(៨៥៥) ១២ ៨៤៨ ៨៤៤<br>អ៊ីម៉ែល: card@online.com.kh<br>srundarith@yahoo.com | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ០៣ | **លោក វង្ស សុខា**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៨៨៣ ០០៨<br>អ៊ីម៉ែល: v.sokha.card@online.com.kh<br>sokhavong2002@yahoo.com | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ០៤ | **លោក ហេង វិជ្ជា**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៨៨៨ ៩២២<br>អ៊ីម៉ែល: phvichea@yahoo.com | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ០៥ | **លោក សុខ សាម៉ែត**<br>លេខទូរស័ព្ទ: (៨៥៥)១៦ ៣៦៩ ៤៧០<br>អ៊ីម៉ែល: s.samait.card@online.com.kh<br>soksamait@yahoo.com | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ០៦ | **លោក សួន រ៉ាស៊ី**<br>លេខទូរស័ព្ទ: (៨៥៥)១៧ ៧១៧ ៨៨៧<br>អ៊ីម៉ែល: snrasy@gmail.com | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី |
| ០៧ | **លោក ទូច តារា**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៨២០ ២៨៧<br>អ៊ីម៉ែល: touch_dara@yahoo.com | មជ្ឈមណ្ឌលគាំពារមាតា និងទារកនៃ ក្រសួងសុខាភិបាល |
| ០៨ | **លោក ភឹម លាន់**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៦២០ ០៧១<br>អ៊ីម៉ែល: phimloan@yahoo.com | មជ្ឈមណ្ឌលគាំពារមាតា និងទារកនៃ ក្រសួងសុខាភិបាល |
| ០៩ | **លោកស្រី ប្រាក់ សោភណនារី**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៩៦៥ ៣៦៨<br>អ៊ីម៉ែល: sophon_prak@ezecom.com.kh | មជ្ឈមណ្ឌលគាំពារមាតា និងទារកនៃ ក្រសួងសុខាភិបាល |
| ១០ | **កញ្ញា ជា ម៉ារី**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៨៩២ ២៦៦<br>អ៊ីម៉ែល: chea.mary50@gmail.com | មជ្ឈមណ្ឌលគាំពារមាតា និងទារកនៃ ក្រសួងសុខាភិបាល |
| ១១ | **លោកស្រី ហ៊ូ និរមិត្តា**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៥៦៣ ៩៧៤<br>អ៊ីម៉ែល: hnirmita@yahoo.com | ក្រសួងកិច្ចការនារី |
| ១២ | **លោកស្រី សុទ្ធ ស៊ីថុន**<br>លេខទូរស័ព្ទ: (៨៥៥) ១៦ ៦៩១ ១៦៧<br>អ៊ីម៉ែល: sithonsoth@yahoo.com | ក្រសួងកិច្ចការនារី |

| | | |
|---|---|---|
| ១៣ | **លោកស្រី ឃ្លោក ប៉េងចន្ធុល**<br>លេខទូរស័ព្ទ : (៨៥៥) ១២ ៦៦២ ៣៤៣<br>អ៊ីម៉ែល: pengchanthol@yahoo.com | ក្រសួងកិច្ចការនារី |
| ១៤ | **កញ្ញា កេត សារ័ត្ន**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៣២៥ ៤៨៦<br>អ៊ីម៉ែល: Ket_saroth@yahoo.com | ក្រសួងកិច្ចការនារី |
| ១៥ | **លោក ហ៊ុច សេរីហ៊ុច**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៦៥៣ ៤៤០<br>អ៊ីម៉ែល: sereyhouch2@yahoo.com | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៦ | **លោក ម៉ាក់ សឿន**<br>លេខទូរស័ព្ទ :(៨៥៥) ១២ ៨២៦ ៦១៧<br>អ៊ីម៉ែល: mak_soeun@camnet.com.kh | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៧ | **លោក អោម ពេជ្រ**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៧៨៣ ៥៦៥<br>អ៊ីម៉ែល: op.pic@yahoo.com | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ១៨ | **លោក អ៊ុំ កុសល**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៨៩៣ ២៦៨<br>អ៊ីម៉ែល: Kosal.Oum@fao.org<br>kosaloum@yahoo.com | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) |
| ១៩ | **លោក ឃិន ម៉េងឃាង**<br>លេខទូរស័ព្ទ: (៨៥៥)១២ ៩២៧ ៤០៦<br>អ៊ីម៉ែល: mengkheang_khin@yahoo.com | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) |
| ២០ | **លោក កុយ រ៉ា**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៥២៧ ៥២៥<br>អ៊ីម៉ែល: ra.koy@fao.org | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) |
| ២១ | **លោក ប៉ិច ស៊ីថន**<br>លេខទូរស័ព្ទ: (៨៥៥) ១៧ ៥២០ ៥៧៣<br>អ៊ីម៉ែល: psithan@yahoo.com | វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM-LI) |
| ២២ | **លោក ប៉ុស សារឿន**<br>លេខទូរស័ព្ទ: (៨៥៥) ១២ ៥២៧ ៥២៥<br>អ៊ីម៉ែល: psaroeung@hki.org | អង្គការ ហេឡែន ខេលល័រ អន្តរជាតិ (HKI) |

**កំណត់សំគាល់:** នៅក្នុងករណីមានតម្រូវការបន្ថែម ឬចំនួនគ្រូបង្គោលមិនគ្រប់គ្រាន់ គ្រូបង្គោលថ្មីនឹងត្រូវបានជ្រើសរើសបន្ថែមទៀតដោយផ្អែកតាមលក្ខណៈសម្បត្តិ និងបទពិសោធន៍ខាងលើ ។

## ៦. លក្ខខណ្ឌការងារ

ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមគ្រូបង្គោលមានចែងដូចខាងក្រោម:

១- សមាជិកក្រុមគ្រូបង្គោលត្រូវមានពេលវេលាក្នុងការចូលរួមវគ្គបណ្តុះបណ្តាល ដោយមានការយល់ព្រមពី និយោជក ឬស្ថាប័នសាមី និងមានការស្នើសុំពីអគ្គលេខាធិការដ្ឋាននៃ ក.ក.ជ.។

២- សមាជិកក្រុមគ្រូបង្គោលនីមួយៗមានកាតព្វកិច្ចបង់វិភាគទានចំនួនប្រាំភាគរយ (៥%) ពីកម្រៃដែលទទួលបានពីសេវាបណ្តុះបណ្តាលជូន អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. សម្រាប់ដំណើរការក្រុមគ្រូបង្គោល។

៣- សមាជិកគ្រូបង្គោល និងស្ថាប័នដែលស្នើសុំ ត្រូវធ្វើរបាយការណ៍ជូន អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. រាល់សកម្មភាពបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

៤- រាល់សម្ភារៈ និងឯកសារយោងផ្សេងៗ (ជាភាសាខ្មែរ និងភាសាអង់គ្លេស) ដែលត្រូវប្រើប្រាស់សម្រាប់វគ្គបណ្តុះបណ្តាល ត្រូវរក្សាទុកនៅ អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ.។

៥- សមាជិកក្រុមគ្រូបង្គោលទាំងអស់ត្រូវចូលរួមប្រជុំរួមគ្នារៀងរាល់ប្រាំមួយ (០៦)ខែម្តង តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ.។

## ៧. ការពិនិត្យ តាមដាន និងវាយតម្លៃ

អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ. អាចនឹងកោះប្រជុំជាមួយក្រុមគ្រូបង្គោលតាមការចាំបាច់ ដើម្បីពិភាក្សាអំពីបទពិសោធន៍ ការកែលម្អ ឬធ្វើបច្ចុប្បន្នកម្ម ទៅលើកម្មវិធីបណ្តុះបណ្តាល ឬការគ្រប់គ្រងចាត់ចែងលើក្រុមគ្រូបង្គោលថ្នាក់ជាតិ។

## ៨. ការធ្វើបច្ចុប្បន្នកម្ម

គោលការណ៍ណែនាំសម្រាប់ក្រុមគ្រូបង្គោលថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀងនិង អាហារូបត្ថម្ភនេះ ត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំតាមការចាំបាច់។